Australian Government
Department of Home Affairs

# សេវាបកប្រែដោយឥតគិតថ្លៃ

## ការកែប្រែសេវាកម្មដោយសារកូវីដ-19

ការប្រើសេវាបកប្រែដែលមានគុណភាពខ្ពស់ជាការសំខាន់ខ្លាំងណាស់សម្រាប់អ្នកដែលគ្មានជំនាញភាសាអង់គ្លេសឬមានតិចតួច ក្នុងអំឡុងពេលមានស្ថានការណ៍កូវីដ-19។

គេគួរប្រើសេវាបកប្រែ ក្នុងករណីអាចរកបាន។

ស្វែងយល់អំពី **កូវីដ-19 និងរោគសញ្ញារបស់វា**។

## តើសេវាបកប្រែដោយឥតគិតថ្លៃជាអ្វី?

លោកអ្នកអាចទទួលបានសេវាបកប្រែដោយឥតគិតថ្លៃ ប្រសិនបើលោកអ្នក ៖

- ស្ថិតនៅក្នុងប្រទេសអូស្ត្រាលី
- មានប័ណ្ណមេឌីឃែរ ហើយនិង
- មានជំនាញភាសាអង់គ្លេសទាប

## តើខ្ញុំអាចរកសេវាបកប្រែដោយឥតគិតថ្លៃដោយវិធីណា?

អ្នកផ្ដល់សេវាទាំងឡាយខាងក្រោមនេះ អាចរកសេវាបកប្រែដោយឥតគិតថ្លៃជំនួសលោកអ្នកបាន ៖

- វេជ្ជបណ្ឌិតឯកជន
- ឱសថការី
- អង្គការក្រៅរដ្ឋាភិបាល
- ភ្នាក់ងារលក់ឬជួលផ្ទះ
- អាជ្ញាធររដ្ឋាភិបាលនៅមូលដ្ឋាន ដូចជាសាលាក្រុងនៅមូលដ្ឋាន
- សហជីពពាណិជ្ជកម្ម ហើយនិង
- តំណាងរាស្ត្រ

សម្រាប់ព័ត៌មានបន្ថែមអំពីសេវាទាំងឡាយនេះ សូមមើលនៅ ទីនេះ។

អ្នកផ្ដល់សេវាទាំងឡាយខាងលើនេះអាចភ្ជាប់ជាមួយអ្នកបកប្រែក្នុងរយៈពេលពីរបីនាទី ដើម្បីធានាឲ្យលោកអ្នកទទួលបានព័ត៌មាននិងឱវាទជាភាសារបស់លោកអ្នក។

## អ្នកបកប្រែ

គេប្រើអ្នកបកប្រែដែលមានសញ្ញាបត្រចេញដោយអាជ្ញាធរជាតិសម្រាប់ផ្តល់សញ្ញាបត្រដល់អ្នកបកប្រែឯកសារនិងផ្ទាល់មាត់ (National Accreditation Authority for Translators and Interpreters (NAATI))។
អ្នកបកប្រែទាំងនោះត្រូវគោរពតាមក្រមសីលធម៌របស់អាជីពដែលតម្រូវឲ្យគេទាំងនោះ ៖

- បកប្រែឲ្យត្រឹមត្រូវ និងដោយស្មោះត្រង់
- រក្សាភាពសម្ងាត់
- មានជំហរអព្យាក្រឹត និងមិនលម្អៀង ហើយនិង
- ប្រកាន់ឥរិយាបថត្រឹមត្រូវតាមអាជីពជានិច្ច

គោលការណ៍របស់សេវាបកប្រែដែលឥតគិតថ្លៃនេះ គឺរកជូនអ្នកដែលមានសញ្ញាបត្រខ្ពស់ជាងគេ។
ដូច្នេះហើយការសុំយកអ្នកបកប្រែជាក់លាក់ណាមួយ មិនត្រូវបានលើកទឹកចិត្តឲ្យធ្វើនោះទេ។

## តើសេវាបកប្រែដោយឥតគិតថ្លៃនេះផ្តល់នូវអ្វីខ្លះ?

- ការបកប្រែតាមទូរស័ព្ទភ្លាមៗ។ សេវានេះមានប្រយោជន៍បំផុតចំពោះការបកប្រែដែលមិនបានគ្រោងទុក ហើយផ្តល់ ៖
  - សេវាអ្នកបកប្រែជាង ៣០០០ នាក់ សម្រាប់ភាសាជាង ១៦០ ភាសា។
  - សេវាបកប្រែដែលមាន ២៤ ម៉ោងក្នុង១ថ្ងៃ ៧ថ្ងៃក្នុង១សប្តាហ៍
  - ការភ្ជាប់ជាមួយអ្នកបកប្រែតាមទូរស័ព្ទដោយត្រូវការពេលពីរបីនាទី។
- ការបកប្រែតាមទូរស័ព្ទដែលមានការកក់ទុកមុន
  - វាមានប្រយោជន៍សម្រាប់ការបកប្រែដែលមានការគ្រោងទុក ឬមួយលោកអ្នកត្រូវការភាសាដែលមិនសូវមានគេប្រើ។